# ការយល់ឃើញរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅកម្ពុជាពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាគម្រោងដែលមានរយៈពេលច្រើនឆ្នាំធ្វើការតាមដាន អំពីលំហសង្គមស៊ីវិលនៅកម្ពុជា ព្រមទាំងកម្រិតយល់ដឹងនិងការអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។

ឆ្នាំ២០១៦ (ឆ្នាំទី១) ឆ្នាំ២០១៨(ឆ្នាំទី២) ឆ្នាំ២០១៩(ឆ្នាំទី៣) និងឆ្នាំ២០២០ (ឆ្នាំទី៤) គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានបញ្ចប់ការស្ទង់មតិសាធារណៈ ដើម្បីវាស់ស្ទង់កម្រិតយល់ដឹងរបស់សាធារណជន អំពីសេរីភាពមូលដ្ឋាន។ ការស្ទង់មតិបានជ្រើសរើសសំណាកងាយៗមកពីគ្រប់ខេត្តក្រុងនៃប្រទេសកម្ពុជា ដើម្បីទទួលបានចំនួនអ្នកឆ្លើយតបទាំងបុរសនិងស្ត្រីស្មើគ្នា។[1] ការឆ្លើយតប**ពីការស្ទង់មតិក្នុងឆ្នាំនីមួយៗមានអ្នកឆ្លើយតបប្រមាណ ១,០០០ នាក់។** ក្នុងឆ្នាំ២០២០ មានចំនួនអ្នកឆ្លើយតបតិចជាងមុនៗ ដោយសារតែជំងឺកូវីដ១៩។




**អ្នកឆ្លើយតបយល់ដឹងអំពីសេរីភាពខាងការបញ្ចេញមតិនិងសេរីភាពខាងជួបប្រជុំ ជាងសេរីភាពខាងសមាគមនិងការចរចាជាសមូហភាព។ ប៉ុន្តែក្នុងឆ្នាំនីមួយៗមានពលរដ្ឋតិចតួចដែលបានរាយការណ៍ថាពួកគេមានការយល់ដឹងខ្លះអំពីសេរីភាពមូលដ្ឋានរបស់បុគ្គលម្នាក់ៗ។**




**មានចំនួនអ្នកឆ្លើយតបតិចតួចជឿជាក់ថាពួកគេមានការយល់ដឹងអំពីសេរីភាពមូលដ្ឋាននីមួយៗ។**[2] ការជឿជាក់នេះបានថយចុះជាងឆ្នាំមុនៗ។




[1] អ្នកឆ្លើយតបមួយចំនួនដែលមិនបានឆ្លើយសំណួរឬឆ្លើយថា "ផ្សេងៗ" បង្ហាញថាពួកគេមិនចង់បង្ហាញពីការកំណត់អត្តសញ្ញាណភេទរបស់ពួកគេឡើយ។ ទោះបីជាបែបនេះក្តី មានភាគរយតិចតួច (តិចជាង៤% ក្នុង១ឆ្នាំ)ដែលតួលេខនេះមិនបានបង្ហាញក្នុងក្រាហ្វប្រៀបធៀបរវាងអ្នកឆ្លើយតបភេទស្រីនិងប្រុសនោះទេ។

[2] **សេរីភាពខាងការបញ្ចេញមតិ** បានឲ្យនិយមន័យថា៖ "ជាសិទ្ធិក្នុងការសម្តែងមតិយោបល់ដោយមិនមានការជ្រៀតជ្រែក និងស្វែងរក ទទួលនិងចែករំលែកព័ត៌មាននិងគំនិតយោបល់គ្រប់ទម្រង់ ទាំងតាមប្រព័ន្ធអ៊ីនធឺណិតនិងក្រៅប្រព័ន្ធអ៊ីនណិតដោយមិនមានការភ័យខ្លាចពីការសងសឹក ការកម្រិតសេរីភាពខ្លួនឯង ឬការដាក់ទោសទណ្ឌ។"

**សេរីភាពខាងសមាគម** បានឲ្យនិយមន័យថា៖ "ជាលទ្ធភាពក្នុងការចូលរួមជាសមាជិកឬជាអ្នកបង្កើតក្រុមដោយសេរី ដើម្បីរួមគ្នាធ្វើសកម្មភាពបញ្ចេញមតិ លើកកម្ពស់ ស្វែងរកឬការពារផលប្រយោជន៍ណាមួយរបស់ពួកគេ។"

**សេរីភាពខាងការជួបប្រជុំ** បានឲ្យនិយមន័យថា៖ "ជាសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការប្រមូលផ្តុំដោយចេតនា ជាបណ្តោះអាសន្ន និងសន្តិវិធីនៅទីកន្លែងឯកជន ឬសាធារណៈក្នុងគោលបំណងជាក់លាក់ណាមួយ។ រួមបញ្ចូលទាំងការធ្វើបាតុកម្ម ប្រជុំ កូដកម្ម ការប្រមូលផ្តុំ ឬការអង្គុយតវ៉ាដោយស្ងៀមស្ងាត់។"

**ការចរចារជាសមូហភាព** បានឲ្យនិយមន័យថា៖ "ជាសិទ្ធិរបស់អង្គការកម្មករនយោជិតមួយឬច្រើនក្នុងការចរចារអនុសញ្ញារួមជាមួយនិយោជក ឬក្រុមនិយោជកក្នុងការកំណត់ប្រាក់ឈ្នួល លក្ខខណ្ឌការងារ អត្ថប្រយោជន៍ ទម្រង់ផ្សេងៗនៃការងារ។ ផលប្រយោជន៍របស់កម្មករនិយោជិតត្រូវបានបង្ហាញតាមរយៈតំណាងសហជីពដែលកម្មករនិយោជិតនោះជាសមាជិក។"

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

SOLIDARITY CENTER AFL-CIO

សមាគមអាដហុក ADHOC

ICNL INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

CC BY NC SA

## សាធារណជនតិចតួចជាងមុនដែលយល់ថាមានសេរីភាពក្នុងការចូលរួមជាមួយសមាគម។




## សាធារណជន**យល់ថាមានសេរីភាពតិចតួចក្នុងការចូលរួមក្នុងជីវភាពនយោបាយ** ចំនួនអ្នកឆ្លើយតបជាស្ត្រីយល់ថាមានសេរីភាពតិចតួចជាងបុរស




ទោះបីជាយ៉ាងណាក៏ដោយ **ស្ទើតែពាក់កណ្ដាលនៃ** អ្នកឆ្លើយតបក្នុងការស្ទង់មតិនៅក្នុងឆ្នាំនីមួយៗបានឆ្លើយថា **ជាសមាជិកនៃសមាគមណាមួយ។** អ្នកឆ្លើយតបជាស្ត្រីជាញឹកញាប់បានឆ្លើយថាបានចូលរួមក្នុងសមាគមមួយ។




## រយៈពេល២ឆ្នាំចុងក្រោយនេះ **សាធារណជនតិចតួចយល់ថាមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី**




## ប្រមាណ១ភាគ៤នៃអ្នកឆ្លើយតបក្នុងឆ្នាំនីមួយៗបានរាយការណ៍ថាជាជនរងគ្រោះដោយសារការចូលរួមជាមួយសមាគម




## សាធារណជនតិចតួចយល់ថាមានសេរីភាពក្នុងការធ្វើកូដកម្មឬបាតុកម្ម ប្រឆាំងនឹងនយោជករបស់ខ្លួន




មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
SOLIDARITY CENTER
សមាគមអាដហុក ADHOC
ICNL INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

CC BY NC SA

សាធារណជនយល់ថាមាន**សេរីភាពតិចតួចក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ** អ្នកឆ្លើយតបជាស្ត្រីក៏ឆ្លើយថាមានសេរីភាពតិចតួចបែបនេះដែរ




សាធារណជនយល់ថា**មានសុវត្ថិភាពតិចតួចក្នុងការរាយការណ៍ព័ត៌មាន**ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ




**សាធារណជនយល់ថាមានសេរីភាពតិចតួចក្នុងការបញ្ចេញមតិតាមបណ្តាញសង្គម** អ្នកឆ្លើយតបជាស្ត្រីក៏យល់ថាមានសេរីភាពតិចតួចដែរ




មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
SOLIDARITY CENTER
ADHOC
ICNL INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

cc BY NC SA